



# ខ្មែរប៉ុស្តិ៍ ស.រ.អា KhmerPost USA

Printing The Cambodian World News

VOL. 05 ISSUE 72 NOV. 19th – DEC. 02nd, 2010


**មាតិការឿង** **ទំព័រ**


១- លទ្ធផលនៃការបោះឆ្នោត....................០៣
២- កិច្ចសម្ភាសន៍រវាងខ្មែរប៉ុស្តិ៍ ....................០៥
៣- រព្រកថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣....................០៧
៤- THE CAMBODIA DAILY ............... ០៨ & ១៣
៥- ស្ត្រីខ្មែរដំបូងបង្អស់ដែលបានធ្វើដំណើរ................១០


## កូនខ្មែរ១៩នាក់ចូលប្រកួត ដំណើ្តមពានរង្វាន់តៃក្វាន់ដូ

**ឡូវែល** : កុមារខ្មែរម្នាក់ និងយុវជនខ្មែរម្នាក់ទៀត បានទទួលមេដាយមាសចំនួនពាក្នុងវិញ្ញាសារបង្ហាញបច្ចេកទេសក្នុងការប្រកួត ដំណើ្តមពានរង្វាន់ក្បាច់គុណតៃក្វាន់ដូមួយដ៏ធំ ដែលស្ថិតនៅក្នុងវិទ្យាល័យឡូវែល កាលពីព្រឹកថ្ងៃទី៧ ខែវិច្ឆិកាកន្លងទៅនេះ ដែលមានការអញ្ជើញចូលរួមជាកិត្តិយសពីលោក អ៊ុមថៃយុន (អគ្គស្ថានកុងស៊ុលកូរ៉េខាងត្បូង ប្រចាំម៉ាសាឈូសែត) លោកគ្រូខ្សែក្រវ៉ាត់ខ្មៅ ណាមហ្វាយអាន ដែលជាអតីតប្រធានសហព័ន្ធតៃក្វាន់ដូប្រចាំរដ្ឋម៉ាសាឈូសែត និង កញ្ញា ហ្វីលីស អ៊ីហ្គីរូ មន្ត្រីនាំពាក្យមន្ទីរពេទ្យកុមារ St. Jude ជាភ្ញៀវកិត្តិយស (តទៅទំព័រទី ១០)



## មានអ្វីប្លែកនៅហ្វីឡាដែលហ្វៀ

### I. ទង់ជាតិប្រទេសកម្ពុជា នៅផ្លូវ BENJAMIN FRANKLIN



នៅសេចក្តីជូនដំណឹងមួយរបស់សាលាក្រុង "ហ្វីឡា" បានឱ្យដឹងថា ទង់ជាតិនៃប្រទេសកម្ពុជា នឹងត្រូវដាក់បន្ថែមនៅមហាវិថី Benjamin Franklin Parway ដែលជាផ្លូវសំខាន់ និងគេស្គាល់ច្រើនជាងគេនៃកណ្តាលក្រុងហ្វីឡាដែលហ្វៀ។ ទង់ជាតិខ្មែរ និងទង់ជាតិប្រទេសថ្មីចំនួន១៩ នឹងត្រូវសម្ពោធដោយលោកអភិបាលក្រុង Michael A.Nutter នៅថ្ងៃសុក្រ ទី១៩ វិច្ឆិកា ឆ្នាំ២០១០ វេលាម៉ោង១១:០០ថ្ងៃត្រង់នាបន្ទប់ទទួលភ្ញៀវរបស់សាលាក្រុង "ហ្វីឡា" (Room 215 City Hall) ។

សហគមន៍ខ្មែរនៅ "ហ្វីឡា" នេះ បានទាមទារឱ្យមានការដាក់ទង់ជាតិខ្មែរនៅលើផ្លូវនេះច្រើនឆ្នាំមកហើយ ដោយសារតែកន្លែងនោះមានដោតទង់ជាតិនៃប្រទេសរាប់រយជាប្រចាំ ហើយសហគមន៍ខ្មែរក៏មានចំនួនច្រើនជាងជនជាតិភាគតិចឯទៀតៗដែរ។ លោក ម៉ាកិលណាទើ ក៏ធ្លាប់បានសន្យានៅក្នុងបទសម្ភាសន៍ជាមួយ "វិទ្យុខ្មែរអាមេរិកាំង" កាលពីបីឆ្នាំមុនដែរថា "បើលោកជាប់ឆ្នោតជាអភិបាលក្រុងលោកនឹងធ្វើឱ្យសំណូមពររបស់សហគមន៍ខ្មែរមួយនេះក្លាយជាការពិតបាន" ។

ពិធីសម្ពោធនេះនឹងត្រូវធ្វើឡើងជាមួយគ្នានឹងពិធីជាប់ឈ្មោះចូលសញ្ជាតិនៃពលរដ្ឋអាមេរិកាំងថ្មីចំនួន២០នាក់ផងដែរ ។ (តទៅទំព័រទី០៥)

## Cambodian Lowellians had been reported experiencing many Robbery cases.

### អំពីឧក្រិដ្ឋកម្មដែលគេមិនហ៊ាននិយាយ



**ឡូវែល** : នៅស្ងៀមស្ងាត់គ្មាននរណានិយាយ ឬផ្សាយឡូវែលតំបន់ដែលសម្បូរដោយខ្មែររស់នៅយ៉ាងច្រើន បន្ទាប់ពីឡុងប៊ិចមក ហាក់ដូចរលកសមុទ្រនៅពេលដែលគ្មានខ្យល់តែតាមពិតរលកក្នុងបាតសមុទ្រមានសភាពគួរឱ្យព្រឺក្បាល។ អគ្រាជា បានតាមដានករណីលួច និងប្លន់ចំនួនជាង៤៥ដង តែក្នុងរយៈពេលខែតុលានៅតំបន់ឡូវែលដែលចែកជាសង្កាត់ចំនួន១៤ ។ ពេលខ្លះមានប្រើអាវុធ ហើយចោរប្លន់ខ្លះទៀតយកទាំងអ្នកបកប្រែខ្លួនមកជាមួយផង។ (តទៅទំព័រទី ០៣)

Lowell Mass: Cambodian Lowellians had been reported experiencing many Robbery cases. Lowell City at large being raid by at least 45 Burglar and Robbery incidents in the month of October and first week of November. Most result in misdemeanor and felony category. At least 4 Robberies were Armed Robbery. These invasion happened in both the residential and business districts and at random times. The community are scared and unwilling to comfort with Khmer Post for comments. In one incident it was reported by a Cambodian community member, whose family had been robbed that the robber brought his own interpreter.

One of the TD Bank was reported had been robbed 3 times. *(Continued to page 03)*


## លិខិតអញ្ជើញមិត្តអ្នកអាន



ចូលរួមក្នុងរាត្រីសមោសរ នាឱកាសសម្ពោធ
សារព័ត៌មានខ្មែរប៉ុស្តិ៍ស.រ.អា ប្រចាំរដ្ឋម៉ាសាឈូសេត



នៅថ្ងៃសៅរ៍ ទី ១៨ ខែ ធ្នូ ឆ្នាំ ២០១០ Saturday, December 18, 2010
វេលាម៉ោង ៦:០០ ល្ងាច ដល់ម៉ោង ១២:០០ យប់ 6:00 PM-12:00 Midlenight
នៅភោជនីយដ្ឋាន សំពៅមាស ទីក្រុងឡូវែល រដ្ឋម៉ាសាឈូសេត
Sompao Meas Hall,450 Chelmsford Street, Lowell, MA 01851
យើងខ្ញុំមានម្ហូបអាហារ និងភេសជ្ជៈជូន ព្រមទាំងក្រុមរបាំអប្សរ ក្រុមកំប្លែង និងរាំលេងកំសាន្តជាមួយតន្ត្រីសម័យ ។ (តម្លៃសំបុត្រវិភាគទាន $35 សូមអញ្ជើញតបមុនថ្ងៃកម្មវិធី)

ព័ត៌មានបន្ថែមសូមទាក់ទងមក លោក មាស សុផល អ្នកតំណាងលេខទូរស័ព្ទ 978-758-8547 អ៊ីម៉ែល sophalusa@gmail.com
និងលោកស្រី ពិន សុបិន្ត នាយិកាពាណិជ្ជកម្មលេខទូរស័ព្ទ 267-253-3947 អ៊ីម៉ែល KhmerpostUSA@gmail.com

## Stop N' Shop Discount Liquor

2305 Admiral Wilson Blvd., Camden, NJ 08105 ,Phone: (856) 365-4377 Fax: (856) 365-1342

REMY MARTIN
V.S.O.P. $35.99 750 ML.
X.O. $99.99 750 ML.

HENESSY V.O.S.P. $39.99 750 ML.

MARTELL CORDON BLUE $93.99 750 ML.

COURVOISIER XO $99.99 750 ML.

ABSOLUT VOLKA $18.09 750 ML. $29.09 1.75 L.

Store Hours :
Mon. -Thurs. 9am - 10pm
Fri - Sat. 9am - Midnight
Sunday Noon - 10p.m
OPEN 365 DAYS



# លទ្ធផលនៃការបោះឆ្នោតឆ្នាំ២០១០ នៅរដ្ឋផែនស៊ីវេនា

លទ្ធផលដែលទទួលបាននៅរដ្ឋផែនស៊ីវេនានេះ បានធ្វើឱ្យប្រធានាធិបតី បារ៉ាក់ អូបាម៉ា ខកចិត្តយ៉ាងខ្លាំង លោកបានមកលើកទឹកចិត្តបេក្ខជនគណបក្សប្រជាធិបតេយ្យរបស់លោក រួមទាំងភរិយាលោក គឺ មីសែល អូបាម៉ា ក៏បានមកកាន់រដ្ឋនេះដូចគ្នាដែរ ក៏ប៉ុន្តែគ្រប់តួនាទីសំខាន់ៗ បានត្រូវគណបក្សសាធារណរដ្ឋយកបានទាំងអស់។

លទ្ធផលនៅ ផេនស៊ីវេនា បានជួយជម្រុញឱ្យសភាជាតិអាមេរិកាំងប្ដូរដៃពីគណបក្សប្រជាធិបតេយ្យមកកាន់តែច្រើនជាគណបក្សសាធារណរដ្ឋបណ្ដាលឱ្យអ្នកស្រីប្រធាន ណាន់ស៊ី បឡូស៊ី ធ្លាក់ពីតំណែងប្រធាន សភាជាតិទៅឱ្យលោក ចន បណើ ទៅវិញ ។ ផេនស៊ីវេនា ឥឡូវនេះមានអភិបាលរដ្ឋ ប៉ាត ធូមី មាន ថម ខប៊ឺត ជាសភារដ្ឋ សុទ្ធតែមកពីគណបក្សសាធារណរដ្ឋទៅវិញ ។

អត្ថបទជាភាសាអង់គ្លេស ដោយ ដាណាលី និង អគ្រា :

*By Dannaly Sam & Audria Chea*

Pennsylvania brought a new leadership into the State House in the 2010 election. Tom Corbett (R) took a hug lead of 54.5% (,782, 940) votes over incumbent Democratic opponent, Dan Onorato who received 45.5% (2,137,6901) favor vote. Along with Corbett, serving as Executive in Chief is his running mate Jim Cawley. Ruling also in GOP is the United State Senator new elected, Pat Toomey who took a lead in a close win of 51% (1,994,737) of votes against incumbent Democratic, Joe Sestak with 49% (1,915,577) of votes.


pat toomey.

Pennsylvania Republican Party also lead in U.S. House of Repre-sentative by 6 seats, Democratic 13 seats and Republican 19 seats.

Historically Pennsylvania governed by the GOP. The Obama administration placed a tremendous investment endorsing democratic U.S. House of Representatives candidates in both the state of Pennsylvania and Illinois. Both President Obama and the First Lady Michelle Obama went to both states at different times to endorse the democratic candidates. The result brought much disappoint - ment to Obama, as his former seat as U.S. House of Representative in Illinois, before running for U.S. Presidency is now taken by the Republican new elected, Mark Steven Kirk. Before the midterm election the Democratic Party held 257 with 1 vacant seat out of 435 seats representing the 50 U.S. states. The Republican Party held only 178 seats with 1 vacant seat. The 2010 election result showed GOP gaining 64 seats in the House of Representative with the total seats won of 240 with Democratic Party only hold 190 seats, which mean the other 3 seats belong to the minority Party. This also mean that Nancy Pelosis is no longer the Speaker of the House. She is still the leader of the minority party now, Democrat. The leader's seat gain that made Republican Party new majority party, included Ohio 8th district Representative John Boehner and California 8th district Representative, John Dennis who beat Nancy Pelo sis in the 2010 race. The new elected Leader and Speaker of the House from the majority party is now John Boehner of Ohio. Now that the GOP is taking control in the U.S. House of Representative and a slim majority of Democratic in the U.S. Senate Upper House, this can only mean making President Obama's job a lot harder to get bills past into laws. Democratic Party used to hold 60 seats in the U.S. Senate House of Representative. Since Scott Brown took the late Ted Kennedy Senate seat this past February, 2010, the Democratic Party loss one golden seat to secure the 60-40 votes. This was why the bi-partisan vote was created to fill the gap.


tom-corbett




YOO'S AUTO SERVICE AND BODY

អបអរសាទរខួបឆ្នាំទី២០
នៃផ្នែកជួសជុលរថយន្ត និងខួបទី១នៃផ្នែកគ្រឿងបន្លាស់



សេវាជួសជុល យូ អរគុណដល់អតិថិជន
ដែលបានគាំទ្រយើងតាំងពី២០ឆ្នាំមក

ពីព្រោះតែមានការគាំទ្រចំនួន២០ឆ្នាំមកហើយនោះ យើងខ្ញុំ និងសងគុណដោយបញ្ចុះថ្លៃជូនអតិថិជនទាំងអស់វិញ នាខួប២០ឆ្នាំរបស់សេវាជួសជុលរថយន្ត យូ ។
សូមពិនិត្យមើលតារាងខាងស្ដាំ

Combo 1 — Oil Change and Filter, Free Tire Rotation (Regular 5W-30 Oil Only UP TO 5Q) — $19.95 +Tax

Combo 2 — State Safty Inspection, State Emissions Inspection — $39.95 +Tax

Combo 3 — Oil Change and Filter, Tire Rotation, State Safty Inspection, State Emissions Inspection — $55.95 +Tax

Combo 1, 2 and 3 Includes Free Visual Inspection

Belts, Hoses, Airfilter, Transmission Fluid, Engine Oil, Power Steering Fluid, Brakefluid, Antifreeze, Windshield Washer Fluid, Windshield Wiper, Brake Pads, Brake Shoes, Tires, Tire Air Pressure, Shocks, Struts, Front end Check, Exhaust System and More

TEL.(215)457-7777/7779 FAX.(215)457-7475
189W. Duncannon Ave., Phila, PA 19120

# ស្ត្រីខ្មែរដំបូងបង្អស់ដែលបានធ្វើដំណើរពីប្រទេសបារាំងមកភ្នំពេញតាមផ្លូវគោគ



(តពីលេខមុន)

ដោយ : ពិន នារីពិទូ

...អ្នកធ្វើដំណើរផ្សងព្រេងទាំងពីរ ស៊ីលវីយ៉ា និង អូរ៉េលី (Sylvia និង Aurélie) បានធ្វើដំណើរតាមរថយន្តតូយ៉ូតារបស់ពួកគេ អស់ជាង១ម៉ឺនគីឡូម៉ែត្រ ហើយពួកគេមានផែនការគ្រោងទុកយ៉ាងល្អមុនពេលចេញដំណើរពួកគេបានបើកបរតាមត្រីវិស័យ ដែលតំរង់ទទួលរាក់ទាក់ និងជាមគ្គុទេសន៍ក្នុងដំណើរកំសាន្តជុំវិញទីក្រុងដើម្បីឱ្យពួកគេទទួលបាននូវពេលវេលាដ៏ល្អក្នុងការស្នាក់នៅតំបន់ Altai ក្នុងរយៈពេលដ៏ខ្លីនេះ និងបាននាំពួកគេឱ្យស្គាល់ផ្ទះដែលបានតុបតែងដោយឈើប្រណីត និងលំអរទៅដោយពណ៌យ៉ាងស្រស់តាមបែបនិយមនៃជនជាតិម៉ុងហ្គោលី ។ ក្នុងជំនួបដ៏រីករាយនេះម្ចាស់ផ្ទះបានផ្ដល់ឱ្យពួកគេនូវអាហារ និងភេសជ្ជៈ ដូចជាទឹកតែទឹកដោះគោ និងនំដុតព្រមទាំងមានឱកាសក្នុងការជិះបានសម្ដែងនូវការនឹករលឹកយ៉ាងខ្លាំងមុនពេលពួកគេចាកចេញទៅ ។

ថ្ងៃទី១១ ខែតុលា ឆ្នាំ២០០៦ អ្នកធ្វើដំណើរផ្សងព្រេងទាំងពីរ ស៊ីលវីយ៉ា និង អូរ៉េលី (Sylvia និង Aurélie) បានធ្វើដំណើរបន្តពីខេត្ត Dezhou អស់ចំងាយ២០០គីឡូម៉ែត្រនាពេលរសៀលក៏បានមកដល់តំបន់ Qufu ដែលបានបន្សល់ទុកនូវកេរ្តិ៍ដំណែលនៃប្រាសាទបុរាណ ដែលបានទាក់ទាញអ្នកទេសចរណ៍ឱ្យចូលទស្សនាគ្រប់



ស៊ីលវីយ៉ា និង អូរ៉េលី ថតនៅចិនដីគោក







ទិសទៅតាមប្រទេសនៅប៉ែកអាស៊ីអាគ្នេយ៍យ៉ាងត្រឹមត្រូវព្រមទាំងបើកបរដោយប្រុងប្រយ័ត្នជៀសវាងការប៉ះទង្គិចជីវិតមនុស្សសត្វ និងដំណាំដាំដុះនៅតាមផ្លូវ ។ គួររំលឹកទៅដល់ប្រជាជននៅតាមតំបន់នីមួយៗផងដែរ ដែលបានស្វាគមន៍អ្នកធ្វើដំណើរផ្សងព្រេងទាំងពីរយ៉ាងកក់ក្ដៅ ដូចជាអ្នកនាង Ariunbayar ដែលធ្វើការខាងផ្នែកឧតុនិយមក្នុងតំបន់ Altai ប្រទេសម៉ុងហ្គោលី បានសេះកំសាន្តនៅក្នុងជនបទផងដែរ ។ រីឯការផ្សងព្រេងធ្វើដំណើរនៅតាមផ្លូវដាច់ស្រយាលឆ្ពោះទៅស្រុក Bay-ankhongor បានប្រទះឃើញខ្ទមពីរបីរបស់អ្នកស្រុក ដោយសារមេឃងងឹតក៏បានសុំអនុញ្ញាតពីអ្នកស្រុក ដើម្បីបោះតង់ក្បែរនោះ ប៉ុន្តែដោយសណ្ដានចិត្តល្អអ្នកស្រុកបានអនុញ្ញាតិឱ្យពួកគេស្នាក់នៅលើខ្ទមរបស់ពួកគេផ្ទាល់ដែលសង់ពីដីឥដ្ឋ អ្នកស្រុកព្រមទាំងក្មេងតូចៗគ្នា ។

ថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៦ ពួកគេធ្វើដំណើរឆ្ពោះទៅណានជីង Nanjing ក្នុងចំងាយផ្លូវ៥០០គីឡូម៉ែត្រ ពី Qufu នៅតាមច្រកចូលទៅខេត្តនីមួយៗតំរូវឱ្យបង់ពន្ធផ្លូវដែលរដ្ឋាភិបាលបានសាងសង់ ពួកគេបានមកដល់ណានជីងក្នុងរយៈពេល១៥ម៉ោង គួរឱ្យកត់សំគាល់ផងដែរចាប់ពីខែតុលា ដល់ពាក់កណ្ដាលខែវិច្ឆិកា ជាពេលវេលាអំណោយផលដ៏ល្អសំរាប់អ្នកទេសចរណ៍ឆ្លងកាត់ប្រទេសចិន សីតុណ្ហភាពមធ្យមនៅរដូវនេះ គឺវាង២២អង្សាសេ មិនក្ដៅមិនត្រជាក់ ទោះជាមានចុះអាប់បន្តិចក៏ដោយ ធ្វើឱ្យអ្នកទេសចរណ៍មានអារម្មណ៍កក់ក្ដៅ ដោយឡែកនៅខែមករា សីតុណ្ហភាពត្រជាក់ខ្លាំងរហូតដល់ក្រោមសូន្យអង្សាសេ និងគួរជៀសវាងការធ្វើដំណើរនៅរដូវក្ដៅដែលសីតុណ្ហភាពក្ដៅបំផុតនៅចន្លោះ៣៥ទៅ៤០អង្សា រដ្ឋាភិបាលប្រទេសនេះបានបើកយុទ្ធការ ដាំដុះរុក្ខជាតិពណ៌បៃតងនៅគ្រប់កន្លែងដើម្បីជួយកាត់បន្ថយអាកាសធាតុក្ដៅខ្លាំង ធ្វើឱ្យទីក្រុងនេះសំបូរទៅដោយសួនឧទ្យាន ដើមឈើពណ៌បៃតងពាសពេញទីក្រុង ។ ការប្រែប្រួលធាតុអាកាសរបស់ប្រទេសនីមួយៗជាកត្តាសំខាន់ក្នុងការកំណត់ពេលវេលា និងទិសដៅក្នុងការធ្វើដំណើរឆ្លងកាត់ ។ ចាប់តាំងពីទស្សវត្សរ៍ឆ្នាំ៩០មកហេដ្ឋារចនាសម្ព័ន្ធទាំងអស់ត្រូវបានផ្លាស់ប្ដូរ ដោយរដ្ឋាភិបាលមានទិសដៅប្រែក្លាយតំបន់នេះឱ្យទៅជាទីក្រុងទំនើប មជ្ឈមណ្ឌលពាណិជ្ជកម្ម និងសេដ្ឋកិច្ចពិភពលោក រួមទាំងចរាចរណ៍ ទំនិញតាមផ្លូវទឹកផងដែរ ។ បច្ចុប្បន្ននេះណានជីង Nanjing បានប្រែក្លាយមុខមាត់របស់ខ្លួនទៅជាតំបន់អេកូទេសចរណ៍ធម្មជាតិដែលពោរពេញទៅដោយសំណង់កំពុងរីកដុះដាលដូចផ្សិត ។ លោក Wang aka Citroen បានជួយពួកគេក្នុងនាមជាមគ្គុទេសក្នុងការស្នាក់នៅប្រទេសចិននេះ ពួកគេតែងទំនាក់ទំនងទៅលោក Wang នៅពេលជួបឧបសគ្គនៅក្នុងទឹកដីធំធេងនេះ ។ នៅតាមព្រំដែនប្រទេសចិន លោក Wang បានចំណាយពេលវេលាយ៉ាងច្រើនជួបសន្ទនាតាមទូរស័ព្ទជាមួយនឹងអាជ្ញាធរចិន ដើម្បីរកដំណោះស្រាយ ។ ព្រឹកស្អែកពួកគេបានចេញដំណើរទៅស្រុក Suzhou ដើម្បីទស្សនាតំបន់ប្រវត្តិសាស្ត្រ ដោយសារពេលវេលាមានកំណត់ពួកគេបានចាប់ផ្ដើមដំបូងក្នុងការឡើងជណ្ដើរ Mausoleum ដែលមានចំនួន៤០០កាំ



លោក Wang aka Citroen

នៅពេលឡើងដល់កំពូលធ្វើឱ្យដកដង្ហើមសឹងមិនដល់គ្នា ដោយសារការនឿយហត់ Mausoleum សាងសង់ដោយបណ្ឌិត Sun Yat Sen ដែលជាស្ថាបត្យករនៃសាធារណរដ្ឋប្រជាធិបតេយ្យបដិវត្តចិននៅដើមសតវត្សរ៍ទី២០នេះ និងបានទៅទស្សនាផ្នូរតំកល់សពរាជវង្សមីង Ming ក្រោយមកពួកគេបានឆ្លៀតឱកាសដើរលើផ្លូវរបៀងដែលមានម្លប់ឈើ និងរូបចំលាក់សត្វធំៗអមសងខាងផ្លូវធ្វើឱ្យមានអារម្មណ៍ធូរស្រាលយ៉ាងខ្លាំង ។ ពួកគេបានជួបជាមួយ Citroen នាពេលថ្ងៃដើម្បីជួយនាំផ្លូវពួកគេបន្តនៅក្នុងទីក្រុងសួនច្បារចំរុះពណ៌នេះ ។ សិល្បៈនៃការចនាសួនច្បារនៅក្នុងប្រទេសនេះធ្វើឱ្យអ្នកមកទស្សនាមានការភ្ញាក់ផ្អើលដោយអ្នករចនាមានគោលបំណងបង្កើតរមណីយដ្ឋានជាលក្ខណៈធម្មជាតិសុទ្ធសាធ ។ ពួកគេបើកបរបន្តក្នុងចំងាយ៥៥គីឡូម៉ែត្រ ក្រោមផ្ទៃមេឃពណ៌ខៀវស្រឡះហាក់ស្វាគមន៍ពួកគេដែលបានមកដល់តំបន់ឆ្នេរ កោះសៀងហៃ Shanghai ពួកគេមានរយៈពេលបីថ្ងៃដើម្បីទស្សនាក្រុងសៀងហៃ Shanghai ។ អាគារ Manhattan និងសំណង់ផ្សេងទៀតដែលកំពុងឈរត្រដែតនៅលើលំហរអាកាសនៅថ្ងៃចុងសប្ដាហ៍នេះអ្នកទេសចរណ៍ក៏ដូចជាអ្នកស្រុកនៅទីនោះបាននាំគ្នាដើរកំសាន្តនៅលើស្ពានយ៉ាងវែងក្នុងទិដ្ឋភាពដ៏ស្រស់ត្រកាលនៃឆ្នេរកោះសៀងហៃ ។

(សូមរង់ចាំអានបន្តនៅលេខក្រោយទៀត)


Attention Parents/Guardians
It's Time to Register for Preschool

FRANKLIN DAY NURSERY

in Partnership with the Philadelphia School District
719 Jackson Street. Philadelphia, PA 19148
(215) 389-2991 / (215) 389-2323

"ហ្វ្រេង់គ្លីន"ថែទាំកុមារពេលថ្ងៃ-រួមសហការជាមួយក្រសួងអប់រំ ហ្វីឡាដែលហ្វៀ
ផ្ដល់សេវាដោយឥតយកកំរៃដល់កុមារអាយុ ៣ទៅ ៥ឆ្នាំ
ដោយកម្មវិធីកិរិតបឋមមុនចូលសាលារៀន

OFFERS: PRE-K COUNTS PROGRAM FREE FOR CHILDREN 3-5 YEARS OF AGE (Child must be 3 years old on or before September 1, 2010)
Free Hours: 8:30 a.m.-3:00 p.m. Open: 7a.m. - 6p.m.

The Program Provides:

- Age Appropriate Child Development Curriculum
- Cultural Enrichment/Cultural Experiences
- Service to Children with Limited English Proficiency
- Family/Parent Involvement Opportunities
- Free Breakfast, Lunch and Snack
- Extended Hours Subsidy Accepted
- State Licensed NAEYC Accredited
- Keystone Stars-3

- កាវិឡូន៍ត្រឹមត្រូវសម្រាប់កុមារ-បង្ហាត់បង្ហាញបទពិសោធន៍ និងចំណេះមានទាំងជួយបង្រួបចំណេះភាសាអង់គ្លេសឱ្យបានគ្រប់គ្រាន់ដល់ក្មេងទៀតផង ។
- ឪពុកម្ដាយ និងមានឱកាសចូលរួមក្នុងការអប់រំ
- អាហារព្រឹក-ថ្ងៃត្រង់ ចំណីចំណុកឥតគិតថ្លៃ
- អាចពន្យារពេលមើលកូនបាន
បំរើដោយអ្នកមានអាជ្ញាប័ណ្ណត្រឹមត្រូវពីរដ្ឋ

The Time to Register is NOW !
ចុះឈ្មោះ ពីឥឡូវ ! (215) 389-2991

If you have any questions or want to pickup a packet, please call the Director @ (215) 389-2991 or email at FDN@FDN.comcastbiz.net . Please return the completed application packet to Franklin Day Nursery ASAP.
*In accordance with applicable Federal and State Civil Rights laws and regulatory requirement, Franklin Day Nursery does not condone discrimination and provides services without regard to race, color, religious creed, disability, ancestry, national origin, Limited English Proficiency (LEP), age, or sex.*


ទទួលថតវីឌីអូ និងរូបថតសន្លឹក
ស្អាតជំនាញផ្នែក អាពាហ៍ពិពាហ៍
ខួបកំណើត បុណ្យទាន និង ពិធីផ្សេងៗ
ទទួលកាត់តវីឌីអូ ការាអូខេ
ទទួលប្តូរប្រព័ន្ធ PAL ទៅ NTSC
ទទួលថតសំរាប់ផ្សាយពាណិជ្ជកម្ម
មានបទពិសោធន៍ជាង ២០ឆ្នាំ
ធានាគុណភាពល្អបំផុត
បានលទ្ធផលយ៉ាងឆាប់រហ័ស
CLICKS STUDIO
Video & Photography
267-506-8639
សូមទាក់ទង:
ពិសិដ្ឋ 410-940-9338
សុភាព 267-767-2655
សួន 267-253-9302
ចំរើន 267-632-4768
Kavei Band
កាវីតន្ត្រី

(Continued from page 01 )

# Cambodian Lowellians...

នៅក្នុងរបាយការណ៍របស់ អគ្រ្ទា គេបានឃើញតំបន់ក្តៅកគុក ដែលសម្បូរដោយការលួច. ប្លន់. ឬឆក់ ដូចជាផ្លូវមីឌុលសិច (១៥ដងខែតុលានេះ) ផ្លូវប្រ៊ីដ. ផ្លូវប៊ីគុន. ផ្លូវវែសហ្វ័ត. ផ្លូវហ្គោរ៉ាម នៃឡូវែលខាងត្បូង ផ្លូវមេរីម៉ាកខាងកើត ឬនៅលើផ្លូវហាយជាដើម ។ ហើយការលួច ប្លន់ ឬឆក់នេះ មិនត្រឹមតែធ្វើលើឯកជនប៉ុណ្ណោះទេ គឺប្លន់ទាំងពាណិជ្ជករ សូម្បីតែធនាគារដែលមានកិច្ចការពារយ៉ាងមាំទាំ ក៏មានការប្លន់ទាំងថ្ងៃត្រង់ដែរ ។

សូមអញ្ជើញតាមដានព័ត៌មានជាភាសាអង់គ្លេសរបស់ អគ្រ្ទា ជា :



The latest robbery was on Friday, October 29th, 2010 at about 11 a.m. The manager of the bank declined to speak with Khmer Post. According to the "Mass. Most Wanted", sponsored by the Mass. Bankers Association, the suspect was described as a "white






male, 5'9" tall, very thin build." The perpetrator described also as wearing mask, demanded for cash, and threaten to shoot employees, although no weapon was physically shown. According to Lowell Sun, at least one person was transported from the scene of the incident by ambulance while police cruisers combed the area looking for a suspect. A Cambodian business owner who located across the street from this incident reported, " At about 12 o'clock at noon on October 29th the police and investigator came into my office and questioned if I had seen anyone unusual around the area. I told them no and they left. Later, my mother told me that before I arrived she saw police car, ambulance, and police went into the business across the street from us. What really happened I don't know."

Per Crime report from Spotcrime.com/ma/Lowell, indicated that the crime of burglar and robbery concentrated in the Highland Neighborhoods. The report showed 14 crime locations were committed in this area. Centralville, South Lowell, and Belvidere Neighborhoods shared equal crime rate of 8 locations. While The Acre Neighborhoods had 3, Back Central had 2, Downtown had 1. Spotcrime.com/ma/Lowell reported to include crime reports from both the Police incident reports and other news sources. Not all alleged perpetrators necessarily found guilty of the crime. High crime rat showed in the middle and the end of October, a few in the first week of November.

A few Cambodian business owners asked not to be identify reported they heard of the burglar and robbery in their business district. Some have their business for 17 years, 5 years, and nearly a year. Most expressed they are not scared and a few expressed safety concern as the day gets dark early. One owner on Westford Street who asked not to be identify stated, "I am scared. Now I try to lock by door when it gets dark out." Khmer Post contacted FBI investigator and Lowell Police Department about the crimes, but they were unable to return the calls and respond for comments.

Data and history of Burglar and Robbery in Lowell from two or more occasions:

Highlands Neighborhoods 14 locations:

Data records of Burglar

15 times on Middlesex St. Last time on 10/30/10

3 times on Westford St. the last time was on 10/29/10

2 times on Branch St & Westford St.

4 times on the second location on Westford St. Last time was on 10/20/10

Data records on Robbery:

4 times on Chelmsford St. Armed Robbery last time on 10/22/10

South Lowell Neighborhoods 8 locations:

Data records of Burglar

13 times on Gorham St.

12 times on Lawrence St.

**Back Central Neighborhoods 2 Locations:**

4 times on High St. Last time on 11/1/10

**Belvidere Neighborhoods 5 Locations:**

2 times on High St. Second time was on 10/28/10

2 times on the second location of High St. Second time was on 10/25/10

6 times on East Merrimack St. Last time was on 10/18/10

**Centralville Neighborhoods 8 Locations:**

Data records of Burglar

3 times on Hildreth St. Last times 11/22/10

6 times on Beacon St. Last times 11/1/10

7 times on Bridge St. Last time on 10/21/2010

ក្រុមហ៊ុនទេសចរណ៍អន្តរជាតិ-អង្គរ
Angkor International Travel Agency




ទទួលផ្ញើរប្រាក់ទៅស្រុកខ្មែរ
សេវាលិខិតឆ្លងដែន
សេវាអន្តោប្រវេសន៍
កក់សណ្ឋាគារ ឬជួលឡាន

USA
4931 N. Old York Rd.
Philadelphia, Pa 19141
Tel: (215) 329-2036
Fax: (215) 329-7176
General Manager NARY PO
angkortravelphilly@yahoo.com

Cambodia Office: Victory Travel (Skin Belle)
No 57B, Eo Street 205 Touls Svay Prey 2.
Phnom Penh, Cambodia.
Ms. Chenda: 023-221069 * 012-851575
Or Mr. Sin Po: 012 429407 * 011-541111.

SERVING SINGAPOR, EVA AIR, CHINA , ASIANA KOREAN AIRLINES,

ក្រុមហ៊ុន ទេសចរណ៍
CENTURY TRAVEL & SERVICE CENTER
904 South 8th Street. Philadelphia, PA 19147
Tel : 215-625-2889; Fax : 215-625-9395
Cell : 267-934-9888; Email : centuryphl@yahoo.com

- បំរើលោកអ្នកដោយគ្រប់ក្រុមហ៊ុនអាកាសចរណ៍ សំរាប់ដំណើរហើរក្នុង និងក្រៅស្រុក
- ជួយរកអ្នកនាំផ្លូវជូនដំណើរទស្សនកិច្ចធ្វើការ
- ពន្យាលិខិតឆ្លងដែនខ្មែរ
- ធ្វើលិខិតអន្តោប្រវេសន៍
- ផ្ញើប្រាក់ប្រថាប់ត្រាបញ្ជាក់លើលិខិតជាផ្លូវការ

- Serve all Airlines
- Domestic & Intl. flights
- Tour Arrangements
- Passport Extension
- Khmer Laissez- Passer
- Immigration
- Tourist Visa
- Notary Public

OFFICE Hours :
Mon - Sat 10:00 A.M - 6:00 P.M
Sun : 12:00 P.M - 5:00 P.M

We Speak Khmer, Chinese, Vietnamese
យើងនិយាយភាសាខ្មែរ_ភាសាចិន_វៀតណាម

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃសុក្រ ទី១២ ខែវិច្ឆិកា ឆ្នាំ២០១០

# Thai General Wants Preah Vihear Border Open

BY SAING SOENTHRITH
THE CAMBODIA DAILY

Less than a week before Thai Prime Minister Abhisit Vejjajiva is set to make a one-day visit to Cambodia, a Thai general has called for the neighboring countries to work together to open a Thai border crossing leading to Preah Vihear temple, Thai media reported yesterday.

An article printed in Thai on an aggregate website run by The Nation Multimedia Group, which also runs the English-language newspaper The Nation, reported that Thai Lieutenant General Thawatchai Samutsakhon said an effort to open a border crossing from Thailand to Cambodia leading to the Preah Vihear temple was in the planning stage. Lt Gen Thawatchai said, however, that it was up to the neighboring governments to make the plans a reality.

The article stated that Lt Gen Thawatchai wants the crossing open sometime next year.

Ministry of Foreign Affairs spokesman Koy Kuong said yesterday that he had heard nothing from the Thai government about the proposed border crossing near the temple, but did say he read about Lt Gen Thawatchai's statements in the media.

Mr Kuong said the border crossing could open if Thai troops leave the disputed area.

Meakh Sina, an adviser to General Pol Saroeun, said the opening of the border crossing could help to continue to reduce tensions between the two neighbors.

"It is both of our wishes to rebuild our relationship and solidarity for peace," he said.

Sar Thavy, deputy governor of Preah Vihear province, said he had not received information from the Thai government about the crossing.

Mr Kuong said he did not know if Mr Abhisit and Prime Minister Hun Sen would speak about the Preah Vihear temple when the Thai premier visits Phnom Penh on Wednesday. Mr Abhisit should participate in the tail end of a two-day, three-summit gathering of regional leaders in Phnom Penh, Mr Kuong said.

After the summit, Mr Hun Sen and Mr Abhisit would have an "official talk," he added.

"I don't know what they will discuss," Mr Kuong said.

Thailand's Ministry of Foreign Affairs did not respond to an e-mailed request for comments about Mr Abhisit's meeting or the border crossing.

*(Additional reporting by Drew Foster)*

# ឧត្តមសេនីយ៍ថៃចង់ឱ្យបើកច្រកឆ្លងកាត់ព្រះវិហារ



ដោយ : សាំង សុឥន្ទ្រិទ្ធ
**The Cambodia Daily**

កាសែតថៃបានរាយការណ៍កាលពីម្សិលមិញថា រយៈពេលមិនដល់មួយសប្ដាហ៍ផង មុនពេលនាយករដ្ឋមន្ត្រីថៃ អភិស៊ីត វិចាជីវ៉ា ធ្វើទស្សនកិច្ចរយៈពេលមួយថ្ងៃនៅប្រទេសកម្ពុជា ឧត្តមសេនីយ៍ថៃម្នាក់បានអំពាវនាវឱ្យប្រទេសជិតខាងនេះសហការគ្នាបើកច្រកឆ្លងកាត់ព្រំដែនថៃឆ្ពោះទៅប្រាសាទព្រះវិហារ ។

អត្ថបទមួយដែលត្រូវបានបោះពុម្ពផ្សាយជាភាសាថៃនៅលើគេហទំព័រមួយដែលបង្ហាញដោយ The Nation Multimerdia Group ដែលដំណើរការកាសែត The Nation ជាភាសាអង់គ្លេសផងដែរនោះ បានរាយការណ៍ថា ឧត្តមសេនីយឯកថៃ លោក ថាវ៉ាតចៃ សាមូសាខន បានថ្លែងថា កិច្ចប្រឹងប្រែងដើម្បីបើកច្រកឆ្លងកាត់ព្រំដែនមួយពីប្រទេសថៃមកកម្ពុជាឆ្ពោះទៅប្រាសាទព្រះវិហារស្ថិតក្នុងដំណាក់កាលធ្វើផែនការ ។ ទោះជាយ៉ាងនេះក្ដី លោកឧត្តមសេនីយឯក ថាវ៉ាតចៃ បានមានប្រសាសន៍ថា វាស្រេចតែរដ្ឋាភិបាលដែលនៅក្បែរខាងទេ ដើម្បីធ្វើផែនការនេះសម្រេចទៅបាននោះ ។

អត្ថបទនេះបានលើកឡើងថា លោកឧត្តមសេនីយ៍ ថាវ៉ាតចៃចង់បើកច្រកឆ្លងកាត់នៅពេលណាមួយនៅឆ្នាំក្រោយ ។

លោក កុយ គួង អ្នកនាំពាក្យរបស់ក្រសួងការបរទេសបានថ្លែងកាលពីម្សិលមិញថា លោកមិនបានឮពីរដ្ឋាភិបាលថៃ អំពីសំណើរបើកច្រកព្រំដែនក្បែរប្រាសាទទេ ប៉ុន្តែលោកបានថ្លែងថា លោកបានអានអំពីសេចក្ដីថ្លែងរបស់ឧត្តមសេនីយ៍ឯករូបនេះនៅក្នុងបណ្ដាញព័ត៌មាន ។ លោក គួង បានថ្លែងថា ច្រកឆ្លងកាត់ព្រំដែននេះអាចបើក ប្រសិនបើទាហានថៃ ចេញពីតំបន់វិវាទ ។

លោក មាឃ ស៊ីណា ទីប្រឹក្សារបស់លោកឧត្តមសេនីយ៍ ប៉ុល សារឿន បានថ្លែងថា ការបើកច្រកឆ្លងកាតព្រំដែននេះ អាចជួយបន្តបន្ថយភាពតានតឹងរវាងប្រទេសជិតខាងទាំងពីរ ។ លោកបានថ្លែងថា "វាជា សេចក្ដីប្រាថ្នារបស់យើង ដើម្បីកសាងទំនាក់ទំនង និងសាមគ្គីភាពរបស់យើង ដើម្បីសុខសន្តិភាព" ។

លោក ស ថាវី អភិបាលខេត្តព្រះវិហារ បានមានប្រសាសន៍ថា លោកមិនបានទទួលព័ត៌មានពីរដ្ឋាភិបាលថៃអំពីច្រកឆ្លងកាត់ព្រំដែននេះទេ ។

លោក គួង បានថ្លែងថា លោកមិនបានដឹងថា តើលោក អភិស៊ីត និងលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងនិយាយអំពីប្រាសាទព្រះវិហារ ឬយ៉ាងណានោះទេ នៅពេលនាយករដ្ឋមន្ត្រីថៃធ្វើទស្សនកិច្ចនៅភ្នំពេញនៅថ្ងៃពុធនេះ ។ លោក គួង បានថ្លែងថា លោក អភិស៊ីត នឹងចូលរួមនៅពេលបញ្ចប់ជំនួបកំពូលនៃក្រុមមេដឹកនាំប្រទេសពា ក្នុងតំបន់រយៈពេលពីរថ្ងៃក្នុងទីក្រុងភ្នំពេញ ។ លោកបានថ្លែងថា បន្ទាប់ពីជំនួបកំពូលនេះ លោក ហ៊ុន សែន នឹងលោក អភិស៊ីត នឹង "មានការចរចាផ្លូវការ" មួយ ។ លោក គួង បានថ្លែងថា "ខ្ញុំមិនដឹងថាលោកទាំងពីរនឹង ពិភាក្សាអំពីអ្វីទេ" ។ ក្រសួងការបរទេសថៃមិនបានឆ្លើយតបទៅនឹងសំណើតាមអ៊ីមែល ដើម្បីធ្វើអត្ថាធិប្បាយអំពីជំនួបរបស់លោក អភិស៊ីត ឬអំពីច្រកឆ្លងកាត់ព្រំដែនទេ" ៕

*(រាយការបន្ថែមដោយ Drew Foster )*

# Garment Factories, Exports Grow With Recovery

BY TIM STURROCK
THE CAMBODIA DAILY

While 49 garment factories shuttered their doors, 70 opened in the first nine months of the year, which saw 21 percent export growth for the sector, according to data released this week from the ministries of Labor and Commerce.

Still, growth levels next year are not expected to return to those seen before the financial crisis and may not lead to proportional job increases, experts said.

Neou Seiha, senior researcher at the Economic Institute of Cambodia, said he expected lower growth next year than this year, as the recovery continues.

"This year is the recovery period and the pace of growth is faster, but next year in 2011 and 2012 the growth will be slower," he said.

Last week, Finance Minister Keat Chhon said exports of garments and textiles would reach \$2.8 billion this year, down from the \$2.9 billion figure reached in 2008.

Ken Loo, secretary-general of the Garment Manufacturers Association in Cambodia, said export growth could reach 15 percent next year, as the country benefits from rule changes in the European Union's Everything but Arms trade scheme for least-developed countries.

He said even with an increase in exports, it would not directly translate to a corresponding spike in jobs and factories. Factories, more and more, are producing more expensive, complicated items, though the added value does not require a proportional amount of workers.

"Obviously, the factories are moving up the value chain so the value of the exports produced is going up. So looking at the value of exports does not give you a complete picture," he said.

Tuomo Poutiainen, chief technical adviser at the International Labor Organization, said that in the first half of the year, 20,000 jobs had been created in the sector, leaving a total of 300,000 jobs and 248 factories.

ILO statistics released earlier this year estimated that in April 2008, a few months before the onset of the crisis, there were 360,000 jobs.

He said he expected jobs to catch up with exports, as there is generally a lag as factories attempt to find skilled workers and factories emerge from the crisis with a better-trained, more efficient staff.

He said that factories also may be waiting to see how many orders they receive.

"The recovery from the crisis can also be a bit tentative," he said.

*(Additional reporting by Hul Reaksmey)*

# រោងចក្រកាត់ដេរនិងការនាំចេញកើនឡើងជាមួយនឹងការរើបឡើងវិញផ្នែកសេដ្ឋកិច្ច

***ដោយ* : TIM STURROCK**

***The Cambodia Daily***

ខណៈដែលរោងចក្រកាត់ដេរចំនួន៤៩បានបិទទ្វាររោងចក្រ ចំនួន៧០បានបើកនៅក្នុងរយៈពេល៩ខែដំបូងនៅឆ្នាំនេះ ដែលបានមើលឃើញកំណើននាំចេញ២១ភាគរយសម្រាប់វិស័យនេះ នេះបើយោងតាមទិន្នន័យដែលចេញនៅសប្ដាហ៍នេះបីក្រសួងការងារ និងពាណិជ្ជកម្ម ។

ក្រុមអ្នកជំនាញបាននិយាយថា ទោះជាយ៉ាងណាកម្រិតកំណើនដែលត្រូវបានមើលឃើញមុនពេលមានវិបត្តិហិរញ្ញវត្ថុឡើយ ហើយប្រហែលជាមិនបណ្ដាលឱ្យមានការកើនឡើងការងារតាមសមាមាត្រនោះទេ ។

លោក នៅ សីហា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា បានមានប្រសាសន៍ថា លោករំពឹងថា កំណើននៅឆ្នាំក្រោយនឹងទាបជាងឆ្នាំនេះ នៅពេលដែលការរើបឡើងវិញនៅតែបន្ត ។

លោកបានមានប្រសាសន៍ថា "នេះគឺជារយៈ ពេលរើបឡើងវិញ និងល្បឿនលឿនជាងមុន ប៉ុន្តែនៅឆ្នាំក្រោយ គឺឆ្នាំ២០១១ដល់ឆ្នាំ២០១២កំណើននេះនឹងធ្លាក់ចុះ" ។

កាត់ពីសប្ដាហ៍មុនលោក គាត ឈន់ ជារដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ បានមានប្រសាសន៍ថា ការនាំចេញសំលៀកបំពាក់ និងវាយនភណ្ឌនឹងឡើងដល់២.៨ពាន់លានដុល្លារនៅឆ្នាំនេះ គឺធ្លាក់ចុះពីតួលេខ២.៩ពាន់លានដុល្លារ ដែលទទួលបានកាលពីឆ្នាំ២០០៨ ។

លោក កែន លូ ជាអគ្គលេខាធិការនៃសមាគមរោងចក្រកាត់ដេរនៅកម្ពុជាបានមានប្រសាសន៍ថា ចំនួននេះអាចឡើងដល់១៥ភាគរយនៅឆ្នាំក្រោយនៅពេលប្រទេសនេះទទួលបានផលប្រយោជន៍ពីការផ្លាស់ប្ដូរវិធាននៅក្នុងផែនការពាណិជ្ជកម្មរបស់សហភាពអឺរ៉ុបដែលមានឈ្មោះថា អ្វីគ្រប់យ៉ាងលើកលែងតែអាវុធសម្រាប់បណ្ដាប្រទេសដែលមានការអភិវឌ្ឍតិចបំផុត ។

លោកបានមានប្រសាសន៍ថា ទោះបីមានការកើនឡើងការនាំចេញក៏ដោយ ក៏វានឹងមិនមានន័យដោយផ្ទាល់ថា ជាការកើណឡើងស្មើគ្នានូវការងារនិងរោងចក្រនោះទេ ។ រោងចក្រកាន់តែច្រើនឡើងៗកំពុងតែផលិតរបស់របរដែលស្មុគស្មាញ និងថ្លៃជាងមុន ប៉ុន្តែលោកបានបន្ថែមថា តម្លៃមិនត្រូវការចំនួនសមាមាត្រនៃកម្មករនោះទេ ។

លោកបានមានប្រសាសន៍ថា "ជាក់ស្ដែងរោងចក្រទាំងនោះកំពុងតែដំឡើងតម្លៃ ដូច្នេះតម្លៃនៃទំនិញនាំចេញដែលផលិតរួចក៏កើនឡើងដែរ ។ ដូច្នេះការសំឡឹងមើលតម្លៃទំនិញនាំចេញមិនផ្ដល់ឱ្យអ្នកនូវរូបភាពពេញលេញឡើយ" ។

Tuomo Poutiainen ជាប្រធានទីប្រឹក្សាផ្នែកបច្ចេកទេសនៅអង្គការពលកម្មអន្តរជាតិបានមានប្រសាសន៍ថា នៅឆមាសទី១នៃឆ្នាំនេះការងារចំនួន ២០.០០០ ត្រូវបានបង្កើតឡើងនៅក្នុងវិស័យនេះ ដោយបន្សល់ទុកនូវការងារសរុបចំនួន៣០០.០០០ និងរោងចក្រចំនួន២៤៨ ។

ស្ថិតិរបស់អង្គការពលកម្មអន្តរជាតិដែលចេញនៅដើមខែនេះបានប៉ាន់ប្រមាណថា នៅក្នុងខែមេសា ឆ្នាំ២០០៨ នៅរយៈពេលពីរបីខែមុនពេល ចាប់ផ្ដើមមានវិបត្តិនេះ មានការចំនួន៣៦០.០០០ ។

លោកបានមានប្រសាសន៍ថា ការនឹងតាមទាន់ការនាំចេញពីព្រោះជាទូទៅមានការពន្យាពេលនៅពេលដែលរោងចក្រនានាព្យាយាមស្វែងរកកម្មករមានជំនាញ ហើយរោងចក្រនានាងើបឡើងពីវិបត្តិនេះមានបុគ្គលិកពូកែ និងមានការបណ្ដុះបណ្ដាលបានល្អ ។

លោកបានមានប្រសាសន៍ថា រោងចក្រនានាក៏ប្រហែលជាកំពុងរង់ចាំមើលថាតើការបញ្ជាទិញប៉ុន្មានដែលពួកគេទទួលបាន ។

លោកបានមានប្រសាសន៍ថា "ការងើបឡើងវិញ ពីវិបត្តិនេះក៏អាចនឹងមិនច្បាស់លាស់តិចតួចដែរ" ៕

*(រាយការណ៍បន្ថែមដោយ ហ៊ុល រស្មី)*

តមកទំព័រទី ០១

# មានអ្វីប្លែកនៅហ្វីឡាដែលហ្វៀ...

## II. វត្តខ្មែរទី៥ នៅហ្វីឡាដែលហ្វៀ

វត្តខ្មែរថ្មីមួយទៀត ទើបនឹងចាប់កំណើតនៅលើផ្លូវ ខ្ញូកាណុន លេខ១០១០ នៅតំបន់ "ឡូគ្នាន់" ខាងជើង ហ្វីឡាដែលហ្វៀ មានឈ្មោះថា "ពោធិ៍វង្ស" វត្តដឹកនាំ ដោយព្រះតេជគុណចៅអធិការមួយអង្គមកពីប្រទេសឥណ្ឌាតំបន់ដែលសមណគោត្តមព្រះពុទ្ធអង្គចាប់កំណើត ។



ឆ្នាំ២០១០ នៅហ្វីឡាដែលហ្វៀនេះ វត្តអារ៉ាម នៃសហគមន៍ខ្មែរ បានកើនចំនួនដល់ទី៥ហើយ ។ វត្តព្រះពុទ្ធរង្សី ផ្លូវ Rithner រីតនើខាងត្បូង បានទិញអាគារ និងដីធំជាប់វត្ត ដើម្បីពង្រីកវត្តឱ្យបានធំរួច ហើយកាលពីដើមខែនេះ ។ រីឯវត្តបាលីល័យ ផ្លូវគ្រីនវិចខងត្បូង ក៏បានទិញដីដ៏ធំទូលាយមួយ នៅផ្លូវលេខ៥៨ ខាងត្បូងឈាងខាងលិច ដើម្បីគ្រោងសង់វត្តដ៏ធំទូលាយមួយនៅទីនោះរួចហើយដែរ ព្រះតេជគុណ ចៅអធិការ សុខឿន សែម ធ្លាប់បានប្រាប់ ខ្មែរប៉ុស្តិ៍ ពេលទទួលអាជ្ញាប័ណ្ណសម្រាប់វត្តថ្មីរបស់ព្រះអង្គថា "ព្រះអង្គគ្រាន់តែបង្វែរទីវត្តឱ្យបានទៅកន្លែងធំទូលាយសម្រាប់ធ្វើបុណ្យតែប៉ុណ្ណោះ រីឯវត្តនឹងធ្វើជាអំណោយដល់អង្គការមនុស្សធម៌ណាមួយឬក៏ត្រូវលក់ប្រសិនបើធនធានសម្រាប់ធ្វើវត្តថ្មីមិនគ្រប់គ្រាន់" ។ ចំណែកឯវត្ត "ព្រះពុទ្ធប្រទានពរ" ខាងត្បូងផ្លូវមីហ្វលីន មិនបានរីកចំរើនដូចវត្តឯទៀតទេ ដោយសារចៅអធិការចាស់ ដែលបានសឹកចាកសិក្ខាបទទៅហើយ បានទាមទារយកវត្តពីឧបាសក ឧបាសិកាជាសម្បត្តិផ្ទាល់របស់លោក ករណីនេះនៅកំពុងរកដំណោះស្រាយវិវាទនៅតុលាការនៅឡើយ ។ នៅសល់វត្ត "សុរិយារង្សី" ខាងជើងពុំទាន់មានការផ្លាស់ប្តូរអ្វីថ្មីទេ លោកតា ហឿង ជាព្រះសង្ឃចាំវស្សាហ្នឹងហ្មំជាងគេ គង់នៅវត្តដែលពុំទាន់មានចៅអធិការនៅឡើយ ចាប់តាំងពីចៅអធិការចាស់ត្រូវទទួលទោសនៅពន្ធនាគារមក ។

វត្តទី៥នេះ កំពុងតែជួសជុល ដើម្បីអាចនឹងធ្វើបុណ្យទានបាន ដឹកនាំដោយព្រះតេជគុណ ពើយ មេត្តា ជាចៅអធិការផង ជាប្រធានវត្តផង ហើយព្រះអង្គជាចៅអធិការនាវត្តដ៏សំខាន់ពីរទៀតនៅប្រទេសឥណ្ឌា គឺ វត្តពុទ្ធគយា មួយ និងវត្ត លំភិនី មួយទៀត ។

ប្រជាពលរដ្ឋខ្មែរប្រមាណ ២ម៉ឺននាក់ ធ្លាប់បានឧបត្ថម្ភដល់វត្តអារ៉ាមទាំងបួនរបស់ខ្លួនយ៉ាងស្វាហាប់ តែពលរដ្ឋនៅតែក្រីក្រ គោរពសីលទាំងប្រាំបានតិចតួច ហើយប្រាថ្នាតែសម្បត្តិបរលោក ។ នៅពីរបីឆ្នាំចុងក្រោយនេះមានការប្រែប្រួលខ្លះៗហើយ ដោយការគ្រប់គ្រងកាន់តែមានតម្លាភាព, ប្រើចំណេះវិទ្យាសាស្ត្របច្ចុប្បន្ន ប្រើយុវជន និងបញ្ញាវន្តបានច្រើន ជាពិសេសផ្តល់សេចក្តីប្រាថ្នាជោគជ័យនៃសម្បត្តិបច្ចុប្បន្នបានច្រើនឡើងហើយដែរ ។

*-ពិន សំខុន-*







DRANOFF ASSOCIATES
Attorneys at Law



"ដ្រាណុហ្វ អាសូស៊ីយេត (DRANOFF ASSOCIATE ) គឺជាមណ្ឌលការពារតាមផ្លូវច្បាប់ ដែលធ្វើការប្រកបដោយភក្តីភាព ដើម្បីតំណាងឱ្យអ្នករងគ្រោះ ដែលមានរបួសរូបរាងកាយ ។

ស្ទីវិន ដ្រាណុហ្វ (STEVEN DRANOFF) គឺជាមេធាវីនៅសាលាក្តីមានបទពិសោធន៍យ៉ាងខ្ពស់ខាងសេវាច្បាប់ ៣៥ឆ្នាំ ។

យើងធ្វើការដោយយកកំរៃពីការងារដែលប្រគល់ឱ្យលោកអ្នកមិនចាំបាច់ចេញថ្លៃចំណាយអ្វីមុននឹងលោកអ្នកទទួលប្រាក់សងពីមុខរបួសលោកអ្នកនោះទេ ។

ជំនួយខាងផ្លូវច្បាប់អាចផ្តល់ជូនជាភាសា ស្បានីស ខ្មែរ វៀតណាម កូរ៉េ និង ចិន ។

● របួសលើរាងកាយ : គ្រោះថ្នាក់រថយន្ត, ឡានឈ្នួល "សិបគា", ឡានត្រឹក, តាក់ស៊ី, ជិះកង់, ថ្មើរជើង, រអិលដួលលើទឹកកក, លើចិញ្ចើមថ្នល់ ឬក្នុងអាគារលក់ទំនិញ, គ្រោះថ្នាក់ដោយបានទិញរបស់ខូចមកប្រើ ឬក៏ឆ្កែខាំ... ។

● ការប្រហែសក្នុងវិជ្ជាជីវៈ និងសិទ្ធិរបស់អតិថិជន : ព្យាបាលតាមវិជ្ជាពេទ្យពុំបានត្រឹមត្រូវ, មរណភាពឥតសមហេតុផល, រាយមាយក្នុងការថែទាំមនុស្ស... ។

DRANOFF ASSOCIATES
121 South Broad Street, Suit 1210, Philadelphia, PA 19107
215-732-3333 (phone) 215-732-8059 (fax)
sdranoff@dranofflaw.com

## តមកពីទំព័រទី ០១ កូនខ្មែរ១៥នាក់ចូលប្រកួតដំណើ្តម...

ហើយនាងក៏ធ្លាប់ទទួលបានពានរង្វាន់ជើងឯកខ្សែក្រវ៉ាត់ខ្មៅផងដែរ ។

